សម្រាប់ការចុះផ្សាយបន្ទាន់ ៖ ថ្ងៃសុក្រទី ១៦ មេសា ២០២០
លេខទំនាក់ទំនងសាលាក្រុង 781-286-8111

# សារលិខិតរបស់សាលាក្រុងជុំវិញ COVID-19៖ ថ្ងៃទី ១៦ មេសា ២០២០

## *ប្រជាជនទាំងអស់ត្រូវពាក់ម៉ាស់ ឬបិទមុខ រាល់ពេលចូលហាងណាមួយ*
## *អំពីអ្នកជំងឺដំបូង ដែលបានចូលស្នាក់នៅ* Quality Inn Site

ថ្ងៃទី ១៣ មេសា ២០២០២ – ក្រុមឆ្លើយតបរហ័សប្រចាំក្រុង Revere នៅតែបន្តការងារយ៉ាងសកម្ម ដើម្បីកាត់បន្ថយល្បឿននៃការឆ្លង និងការរាលដាលនៃជំងឺ COVID-19។ ហើយបានរៀបចំវិធានការរួចជាស្រេចដើម្បីទប់ទល់នឹងការឆ្លងនានា។ នៅថ្ងៃនេះ នាយកដ្ឋានសុខាភិបាលរបស់រដ្ឋ Massachusetts បានផ្តល់ដំណឹងមកកាន់ក្រុមសុខាភិបាលប្រចាំក្រុង Revere ថា បានរកឃើញអ្នកឆ្លងមេរោគ COVID-19 ចំនួន 538 នាក់ នៅក្នុងក្រុង Revere។

យប់នេះ លោកអភិបាល Arrigo និងប្រធានក្រុមប្រឹក្សាសុខភាពប្រចាំក្រុង Revere លោក Nathalee Kong នឹងធ្វើសេចក្តីរាយការណ៍ពីស្ថានភាពនានាពីជំងឺ COVID-19 ក៏ដូចជាត្រៀមឆ្លើយនូវសំនួរផ្សេងៗតាមរយៈដែលប្រជាជនបានសួរតាមរយៈ Facebook Page។ អ្នកអាចចូលមើលការប្រជុំ Town Hall ដោយចុចទីនេះ។

កាលពីម្សិលមិញ ក្រុមប្រឹក្សាសុខភាព បានចេញសេចក្តីណែនាំឲ្យប្រជាជនម្នាក់ៗដែលមានអាយុចាប់ពី៥ឆ្នាំ ធ្វើការបិទបាំងមុខនៅរាល់ពេលចូលក្នុងអគារសាធារណៈ នៅពេលប្រើមធ្យោបាយធ្វើដំណើរសារធារណៈ ពេលជិះតាក់ស៊ី ពេលចូលទៅចាក់សាំង ឬនៅពេលណាដែលអ្នកមានសកម្មភាពនៅខាងក្រៅផ្ទះ។ ហាងទំនិញ ឬបម្រើសេវានានាមានសិទ្ធក្នុងការហាមឃាត់មិនឲ្យអ្នកចូល បើអ្នកមិនពាក់ម៉ាស់ ឬបិទបាំងមុខ។

អ្នកជំងឺដំបូងបានចូលមកសម្រាកព្យាបាលនៅ Quality Inn ក្នុងថ្ងៃនេះ។ The Inn នឹងផ្តល់ជូននូវសេវាថែទាំសុខភាព និងដំណោះស្រាយនានាដល់ប្រជាជនរបស់ Chelsea និង Revere ដែលរស់នៅតំបន់មានមនុស្សច្រើន និងមានហានិភ័យខ្ពស់ក្នុងការឆ្លងជំងឺ។ បុគ្គលគ្រប់រូប អាចមកសម្រាកព្យាបាលនៅ The Inn បាន ដោយពួកគេត្រូវមានលក្ខខណ្ឌផ្សេងៗដូចជា៖ ជាប្រជាជនដែលរស់នៅក្រុង Revere ឬ Chelsea មានផ្ទុកមេរោគ COVID-19 និងត្រូវបានគ្រូពេទ្យបញ្ជាក់ថាអាចព្យាបាលជំងឺបានដោយមិនបាច់ប្រើថ្នាំ ក៏ដូចជាអ្នករស់នៅក្នុងស្ថានភាព ឬស្ថិតក្នុងដំណាក់កាលដែលតម្រូវឲ្យរស់នៅម្នាក់ឯង។ មន្ត្រីសាធារណៈប្រចាំ Chelsea និង Revere នឹងពិគ្រោះយោបល់ជាមួយអ្នកជំនាញវេជ្ជសាស្ត្រ ដើម្បីបញ្ជាក់ថាបុគ្គលបែបណា ត្រូវដែលស្របតាមលក្ខខណ្ឌ អាចចូលទៅសម្រាកព្យាបាលនៅទីនោះបាន៕